មគ្គទេសក៍សម្រាប់បង្រៀននិងរៀន

ប្រវត្តិវិទ្យា



© រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយ

លោក ឈិន ចណ្ឌី

ហាមដកស្រង់ខ្លឹមសារទាំងស្រុងក្នុងផ្នែកណាមួយនៃសៀវភៅនេះយកទៅរៀបរៀងធ្វើជាសៀវភៅផ្ទាល់ខ្លួនសម្រាប់ធ្វើអាជីវកម្ម ដោយគ្មានការអនុញ្ញាត។

បោះពុម្ពលើកទី១

អានមុនចាប់

សៀវភៅ**«មគ្គទេសក៍សម្រាប់បង្រៀន និងរៀន ប្រវត្តិវិទ្យា ថ្នាក់ទី៨»** នេះ ជាសៀវភៅដ៏ល្អមួយសម្រាប់សិស្សានុសិស្សយកមកធ្វើជាមគ្គទេសក៍សម្រាប់រៀន និងជាឯកសារជំនួយស្មារតី ដើម្បីឱ្យយល់ពីខ្លឹមមេរៀននីមួយៗកាន់តែច្បាស់លាស់បន្ថែមទៀត។ ទន្ទឹមនឹងនេះលោកគ្រូ អ្នកគ្រូ ក៏អាចយកសៀវភៅនេះមកធ្វើជាមគ្គទេសក៍សម្រាប់បង្រៀនសិស្សបានផងដែរ ព្រោះសៀវភៅនេះខ្ញុំបានរៀបចំឡើងតាមលំដាប់លំដោយនៃខ្លឹមសារមេរៀននីមួយៗគ្រប់ចំណុចទាំងអស់ ដែលមាននៅក្នុងសៀវភៅសិក្សាគោលថ្មី។

កូនសៀវភៅដ៏តូចស្តើងនេះកើតចេញពីការប្រមូលផ្តុំនូវចំណេះដឹងសំខាន់ៗពីលោកគ្រូ អ្នកគ្រូ ដែលបានបង្ហាត់បង្រៀនខ្ញុំ បានកន្លងមក ព្រមទាំងការចម្រាញ់ចេញពីឯកសារនានាដែលខ្ញុំ ធ្លាប់បានអានស្រាវជ្រាវ និងការសម្រិតសម្រាំងតាមខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី៨ថ្មី របស់ក្រសួងអប់រំ យុវជន និងកីឡា។ ខ្ញុំបានចងក្រងសៀវភៅនេះឡើង ដើម្បីធ្វើជាមគ្គទេសក៍សម្រាប់បង្រៀនរបស់ខ្ញុំផ្ទាល់ខ្លួន និងទុកជាឯកសារជំនួយស្មារតីដល់សិស្សានុសិស្សសម្រាប់ស្រាវជ្រាវបន្ថែម។

ទោះបីជាខ្ញុំខិតខំព្យាយាមសម្រិតសម្រាំងយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតដោយជៀសវាងមិនរួចនោះឡើយ ដូច្នេះខ្ញុំសង្ឃឹមថាសិស្សានុសិស្ស និស្សិត លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាទាំងឡាយមេត្តាយោគយល់អធ្យាស្រ័យចំពោះកំហុសឆ្គងទាំងនេះដោយក្តីអនុគ្រោះ និងចូលរួមរិះគន់ដើម្បីស្ថាបនាដើម្បីឱ្យសៀវភៅនេះកាន់តែល្អទ្វេឡើង នៅពេលបោះពុម្ពលើកក្រោយៗទៀត។ សូមអរគុណ!


រតនគិរី ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៦

ឈិន ចណ្ឌី



ជូនចំពោះ

.....



“សៀវភៅជាកាដូដ៏មានតម្លៃសម្រាប់មនុស្សជាទីស្រឡាញ់របស់អ្នក”

មាតិកា

ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជាសម័យក្រោយអង្គរ

មេរៀនទី១ សម័យចតុមុខ(១៤៣៤-១៥២៩)

១-ពាក្យគន្លឹះ..... ១

២-រាជវង្សខ្មែរសម័យចតុមុខ ២

៣-សង្គ្រាមរំដោះខេត្តខាងលិចពីសៀម ៤

៤-ព្រះបាទធម្មរាជាពឹងសៀមក្នុងវិបត្តិរាជវង្សខ្មែរ..... ៥

៥-សង្គ្រាមរវាងព្រះបាទស្រីសុគន្ធបទនិងស្តេចកន..... ៧

៦-សង្គ្រាមរវាងស្តេចកន និងព្រះចន្ទរាជា(១៥១៦-១៥២៥)..... ៨

៧-សំណួរប្រតិបត្តិ ១០

មេរៀនទី២ សម័យលង្វែក

១-ពាក្យគន្លឹះ..... ១៣

២-ស្ថានភាពភូមិសាស្ត្របន្ទាយលង្វែក..... ១៣

៣-ព្រះរាជាសម័យលង្វែក..... ១៥

៤-ស្ថានភាពនយោបាយ..... ១៧

៥-ស្ថានភាពសេដ្ឋកិច្ច ១៧

៦-ការបែកបាក់បន្ទាយលង្វែក និងផលវិបាក..... ១៨

៧-សំណួរប្រតិបត្តិ ២០

មេរៀនទី៣ សម័យឧដុង្គ

១-ពាក្យគន្លឹះ..... ២១

២-ព្រះបាទស្រីសុរិយោពណ៌ និងស្នាព្រះហស្ត(១៦០៣-១៦១៣)..... ២១

៣-ព្រះបាទជ័យជេដ្ឋាទី២(១៦១៨-១៦២៨)..... ២៣

៤-ព្រះបាទអង្គអេង(១៧៧៩-១៧៩៦)..... ២៦

៥-ព្រះអង្គចន្ទ(១៨០៦-១៨៣៤)..... ២៧

៦-ប្រទេសកម្ពុជាក្រោមអំណាចយួន..... ២៧

៦-ព្រះបាទអង្គដួង និងស្នាព្រះហស្ត(១៨៤០-១៨៦០)..... ២៩

៧-សំណួរប្រតិបត្តិ..... ៣២

មេរៀនទី៤ អាណាព្យាបាលបារាំង(១៨៦៣-១៩៥៣)

១-ពាក្យគន្លឹះ..... ៣៣

២-ការមកដល់របស់បារាំង..... ៣៤

៣-ខ្លឹមសារសន្ធិសញ្ញាបារាំង-ខ្មែរថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣..... ៣៦

៤-អនុសញ្ញាបារាំង-ខ្មែរថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤..... ៣៨

៥-បញ្ហាដែនដីកម្ពុជាក្រោម..... ៤១

៦-សំណួរប្រតិបត្តិ..... ៤២

ជំពូកទី២ ប្រវត្តិសាស្ត្រតំបន់មជ្ឈិមសម័យ និងនវសម័យ

មេរៀនទី១ រដ្ឋចម្ប៉ា

១-ពាក្យគន្លឹះ..... ៤៤

២-ទីតាំងភូមិសាស្ត្រ និងកំណកំណើតរដ្ឋចម្ប៉ា..... ៤៤

៣-ទំនាក់ទំនងចិន និងចម្ប៉ា..... ៤៦

៤-ទំនាក់ទំនងជាមួយខ្មែរ..... ៤៧

៥-ទំនាក់ទំនងជាមួយជាយវៀត និងការបាត់បង់ទឹកដី..... ៤៨

៦-វាសនាជនជាតិចាម.....៤៨

៧-ប្រពៃណីជនជាតិចាម.....៤៩

៨-សំណួរប្រតិបត្តិ.....៤៩

មេរៀនទី២ រដ្ឋដាយវៀត

១-ពាក្យគន្លឹះ.....៥០

២-ទីតាំងភូមិសាស្ត្រ និងការកកើតរដ្ឋ.....៥១

៣-អំណាចក្នុងរាជវង្សលី និងជិន.....៥២

៤-សេដ្ឋកិច្ចដាយវៀត.....៥៣

៥-សង្គមដាយវៀត.....៥៥

៦-សំណួរប្រតិបត្តិ.....៥៦

មេរៀនទី៣ រដ្ឋអយុធ្យា

១-ពាក្យគន្លឹះ.....៥៧

២-ទីតាំងភូមិសាស្ត្រ.....៥៧

៣-ការបង្កើតរដ្ឋ.....៥៨

៤-រដ្ឋអយុធ្យា និងអរិយធម៌ខ្មែរ.....៥៩

៥-ក្រុងអយុធ្យាក្រោមការត្រួតត្រារបស់ភូមា.....៦០

៦-ព្រះចៅ តាក់ស៊ីន និងរាជវង្សចក្រី.....៦០

៧-សំណួរប្រតិបត្តិ.....៦១

មេរៀនទី៤ រដ្ឋឡានសាង

១-ពាក្យគន្លឹះ.....៦២

២-ជនជាតិដើមនៅឡាវមុនសតវត្សទី១៤.....៦២

៣-កំណកំណើតរដ្ឋឡានសាង ៦៣

៤-ស្ថានភាពនយោបាយ ៦៤

៥-ស្ថានភាពសង្គម និងវប្បធម៌ ៦៥

៦-សំណួរប្រតិបត្តិ ៦៦

មេរៀនទី៥ ពិភពម៉ាឡេ

១-ពាក្យគន្លឹះ ៦៧

២-ស្ថានភាពភូមិសាស្ត្រ ៦៧

៣-ស្ថានភាពជំនួញ ៦៩

៤-ការមកដល់នៃពួកអឺរ៉ុប ៧០

៥-អរិយធម៌ពិភពម៉ាឡេ ៧១

៦-សំណួរប្រតិបត្តិ ៧២

ជំពូកទី៣ ប្រវត្តិសាស្ត្រពិភពលោកមជ្ឈិមសម័យ និងនវសម័យ

មេរៀនទី១ របបសក្តិភូមិក្នុងមជ្ឈិមសម័យ

១-ពាក្យគន្លឹះ ៧៤

២-កំណើតនៃរបបសក្តិភូមិ ៧៤

៣-ឥរិយាបថបែបសាសនា និងទំនៀមទម្លាប់ក្នុងសម័យសក្តិភូមិ ៧៦

៤-សង្គមសក្តិភូមិ ៧៨

៥-សំណួរប្រតិបត្តិ ៨១

មេរៀនទី២ ការរុករកដីថ្មីរបស់ពួកអឺរ៉ុប

១-ពាក្យគន្លឹះ ៨២

២-ការរុករកធំៗ ៨២

៣-ការច្បាំងដណ្តើមយកដីថ្មី..... ៨៥

៤-ចក្រភពនៃពួកអាណានិគមនិយម..... ៨៧

៥-សំណួរប្រតិបត្តិ..... ៨៩

មេរៀនទី៣ បដិវត្តន៍គហបតីអង់គ្លេសសតវត្សទី១៧

១-ពាក្យគន្លឹះ..... ៩០

២-ការបរាជ័យនៃរបបផ្តាច់ការ..... ៩០

៣-របបសាធារណរដ្ឋក្រំរ៉ែល..... ៩២

៤-របបរាជាធិបតេយ្យអាស្រ័យសភា..... ៩៣

៥-សំណួរប្រតិបត្តិ..... ៩៤

មេរៀនទី៤ បដិវត្តន៍គហបតីបារាំងសតវត្សទី១៨

១-ពាក្យគន្លឹះ..... ៩៥

២-បដិវត្តន៍គហបតីឆ្នាំ១៧៨៩..... ៩៦

៣-របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ..... ៩៩

៤-បរាជ័យរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ..... ១០០

៥-ពួកសៀរ៉ុងដាំង និងពួកម៉ុងតាញ៉ា..... ១០១

៦-សំណួរប្រតិបត្តិ..... ១០៤

មេរៀនទី៥ ការបង្កើតសហរដ្ឋអាម៉េរិក

១-ពាក្យគន្លឹះ..... ១០៥

២-ប្រជាជនសហរដ្ឋអាម៉េរិក..... ១០៥

៣-សង្គ្រាមទាមទារឯករាជ្យនៃរដ្ឋទាំង១៣..... ១០៨

៤-សំណួរប្រតិបត្តិ..... ១១២

ឯកសារយោង.....


មតិអ្នកសិក្សា.....

ទំនាក់ទំនង.....

ជំពូកទី ១

ប្រវត្តិសាស្ត្រកម្ពុជា

សម័យក្រោយអង្គរ



ផែនទីរាជធានីឧដុង្គ ដែលគូសដោយជនជាតិហូឡង់នៅឆ្នាំ១៧៤៩ ដែលគេនៅបន្តហៅថា លង្វែក។

<u>សម្គាល់:</u>

១-កោះចិន	៣-ពាមជំនីក	៥-ភ្នំព្រះរាជទ្រព្យ
២-កំពង់ហ្លួង	៤-វាំងឧដុង្គ(វត្តចាស់	៦-បន្ទាយលង្វែក

មេរៀនទី ១

សម័យចតុមុខ(១៤៣៤-១៥២៩)

សំណួរ-ចម្លើយ

១-ពាក្យគន្លឹះ

- **អន្តរាគមន៍៖** ការជួយអះអាងសម្រុះសម្រួល ការចេញពាំងមុខដោយអំណាចក្នុងរឿងអ្វីមួយ។
- **សមរភូមិ៖** ទីចម្បាំង ទីកន្លែងប្រយុទ្ធគ្នារបស់ទ័ព។
- **ឧបរាជ៖** ព្រះរាជាបន្ទាប់ គឺក្សត្រិយ៍ដែលមានរាជស័ក្តិរងបន្ទាប់ក្សត្រិយ៍ទ្រង់រាជ្យ។
- **ប្រពាតព្រៃ៖** ចេញឃ្លាតចាកលំនៅប្រក្រតី (ប្រើចំពោះតែរាជស័ព្ទ) ស្តេចចេញប្រពាតព្រៃ គឺស្តេចចេញទៅក្រសាលព្រៃ កម្សាន្តព្រះរាជហឫទ័យ។
- **ព្រះខ័នរាជ្យ[1]៖** ព្រះខ័នសម្រាប់រាជ្យ ព្រះខ័នសម្រាប់ព្រះមហាក្សត្រគ្រងរាជ្យ។

[1] គ្រឿងចាំបាច់មួយក្នុងចំណោមគ្រឿងចាំបាច់ទាំង៥សម្រាប់ប្រើក្នុងពិធីរាជាភិសេក។ **គ្រឿងបញ្ចក្សេត្រ** គឺជាគ្រឿងចាំបាច់ទាំងប្រាំសម្រាប់ប្រើក្នុងពិធីរាជាភិសេករួមមាន៖ *១-ព្រះកុដរាជ្យ ២-ព្រះខ័នរាជ្យ៣ ៣-ព្រះវាលវីជនី ៤-ព្រះស្វេតច្ឆត្រ ៥-ព្រះសុវណ្ណបាទុកា*។ **ព្រះបញ្ចក្សេត្រ** ទេវរូបទាំងប្រាំសម្រាប់ប្រើក្នុងពិធីរាជាភិសេកឡើងសោយរាជ្យសម្បត្តិរួមមាន៖ *១-ព្រះឥសូរ ២-ព្រះនាងឧមា ៣-ព្រះនារាយណ៍ ៤-ព្រះគណេស (ព្រះវិឃ្នេស) ៥-ព្រះចន្ទី (ខ្លះហៅថាព្រះពលទេព)*។

២-រាជវង្សខ្មែរសម័យចតុមុខ


១-តើរាជធានីចតុមុខមានឈ្មោះពេញដូចម្តេច?

- គឺ «ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតី សិរីធរបវរឥន្ទបត្តបុរីរដ្ឋ រាជសីមាមហានគរ»។

២-តើព្រះបាទពញាយ៉ាតមានស្តាព្រះហស្តអ្វីខ្លះ?

- រំដោះរាជធានីអង្គរពីសៀម
- កសាងរាជធានីចតុមុខ
- ធ្វើឱ្យប្រទេសជាតិមានសេចក្តីសុខសាន្ត។

រាជវង្សខ្មែរសម័យចតុមុខ



៣-តើព្រះបាទពញាយ៉ាតមានអ្នកម្នាងប៉ុន្មានអង្គ? ព្រះនាមអ្វីខ្លះ?

❑ **មានបីអង្គគឺ៖**

- អ្នកម្នាងទេវី
- អ្នកម្នាងបទុមកេសរ

- អ្នកម្នាងស៊ីសាង៉ាម(សៀម)។

៤-តើព្រះបាទពញាយ៉ាតមានបុត្រាប៉ុន្មានអង្គ? ព្រះនាមអ្វីខ្លះ?

❑ **មានបីអង្គគឺ៖**

- ព្រះបាទនរាយរាជា
- ព្រះបាទស្រីរាជា
- ព្រះបាទធម្មរាជា។

៥-តើព្រះបាទស្រីសុគន្ធបទមានចំណូលចិត្តដូចម្តេច?

- ព្រះអង្គចូលចិត្តប្រមាញ់ នេសាទ និងប្រពាតព្រៃ។

៦-តើមានកត្តាអ្វីខ្លះជំរុញឱ្យព្រះបាទពញាយ៉ាតមកតាំងរាជធានីនៅចតុមុខ?

- ជាទីតាំងយុទ្ធសាស្ត្រ ងាយស្រួលការពារពីសត្រូវ
- គេចពីសត្រូវឈ្លានពាន(សៀម)
- ដីមានជីជាតិងាយស្រួលក្នុងការធ្វើកសិកម្ម
- ជាទីប្រសព្វនៃផ្លូវជំនួញទាំងផ្លូវទឹក និងផ្លូវគោក
- សម្បូរផ្លូវទឹកក្នុងការធ្វើកសិកម្មនិងជំនួញ
- ព្រះបាទពញាយ៉ាតប្រហែលមានស្រុកកំណើតនៅភាគខាងត្បូង ជាប់មាត់ទន្លេមេគង្គ
- ភាគខាងត្បូងមានប្រជាជនច្រើន មានធនធានដើម្បីកសាងសេដ្ឋកិច្ចជាតិ។

៧-តើព្រះបាទពញាយ៉ាតយកអ្នកម្នាងស៊ីសាង៉ាម(សៀម)មកធ្វើជាស្នំត្រឹមត្រូវដែរឬទេ? ហេតុអ្វី?

- ជារឿងមិនត្រឹមត្រូវទេ ព្រោះសៀមជាសត្រូវរបស់ខ្មែរ ដែលបានលើកទ័ពចូលឈ្លានពានខ្មែរជាញឹកញាប់។ ម្យ៉ាងទៀតទង្វើនេះបានបង្កឱ្យមានវិបត្តិរាជវង្សខ្មែរនៅពេលក្រោយទៀត ដែលបង្កឱ្យប្រទេសកម្ពុជាបាត់បងអធិបតេយ្យភាព និងបូរណភាពដែនដី។

៣-សង្គ្រាមរំដោះខេត្តខាងលិចពីសៀម

១-តើព្រះបាទស្រីរាជាបានរៀបចំផែនការដូចម្តេចខ្លះ ដើម្បីរំដោះយកខេត្តខាងលិចពីសៀមវិញ?

- ចាត់តាំងអាជ្ញាធរខេត្តក្រុង ស្រុក ឃុំឱ្យមាំមួន
- កសាងកម្លាំងទ័ពទាំងជើងគោក ជើងទឹក ព្រមទាំងភស្តុភារសឹកស្បៀង និងបង្វឹកទ័ពបម្រុងឱ្យខ្លាំងពូកែ និងស្ទាត់ជំនាញ
- ព្រះអង្គបានដឹកនាំទ័ព និងចាត់តាំងព្រះស្រីសុរិយោទ័យជាក្មួយឱ្យប្រមូលកម្លាំងទ័ព និងស្បៀង ដើម្បីឧបត្ថម្ភសមរភូមិមុខ
- ព្រះធម្មរាជា ចាត់តាំងឱ្យនៅថែរក្សារាជធានីចតុមុខ

២-តើព្រះបាទស្រីរាជាដឹកនាំទ័ពរំដោះបានខេត្តណាខ្លះពីសៀម?

- រំដោះបានខេត្តដូចជា នគររាជសីមា បស្ចិមបុរី រយ៉ង និងចន្ទបុរី។

៣-ហេតុអ្វីបានជាផែនការរំដោះយកខេត្តខាងលិចពីសៀមរបស់ព្រះបាទស្រីរាជាត្រូវបរាជ័យ?

❑ **បានជាផែនការរំដោះយកខេត្តខាងលិចត្រូវបរាជ័យព្រោះ៖**

- នៅសមរភូមិក្រោយមានវិបត្តិរាជវង្សផ្ទុះឡើង ដើម្បីដណ្តើមរាជបល្ល័ង្កពីសំណាក់ធម្មរាជា និងស្រីសុរិយោទ័យ

- ចំណែកនៅសមរភូមិមុខឧកញ៉ាចក្រីម៉ែនត្រូវរបួស ហើយទទួលមរណភាព ក៏បានរៀបចំធ្វើបុណ្យឱ្យសមកិត្តិយស និងស្នាដៃរបស់ចក្រីម៉ែន
- ការលោភអំណាចរបស់ធម្មរាជាបានដាក់ប្រទេសខ្មែរក្រោមចំណុះសៀមនៅក្នុងឆ្នាំ១៤៨៥។

៤-ព្រះបាទធម្មរាជាពឹងសៀមក្នុងវិបត្តិរាជវង្សខ្មែរ

១-ហេតុអ្វីបានមានវិបត្តិក្នុងរាជវង្សខ្មែរនាស.វ.ទី១៥?

- បានជាមានវិបត្តិក្នុងរាជវង្សខ្មែរព្រោះ ព្រះស្រីសុរិយោទ័យបះបោរដណ្តើមអំណាចពីព្រះបាទស្រីរាជា ចំណែកព្រះធម្មរាជាក្បត់ចង់បានអំណាចដែរ បានបិទក្រុងចតុមុខមិនឱ្យព្រះបាទស្រីរាជាចូល។

២-ហេតុអ្វីបានជាព្រះស្រីសុរិយោទ័យបះបោរដណ្តើមអំណាច?

- ព្រោះព្រះស្រីសុរិយោទ័យទ្រង់គិតថា រាជ្យសម្បត្តិគឺជារបស់ព្រះអង្គ ខណៈព្រះអង្គជាបុត្រាច្បងរបស់ស្តេចអង្គមុន(នរាយណ៍រាជា) តាមច្បាប់តំណរាជ្យ ត្រូវបុត្រាច្បងឡើងសោយរាជ្យបន្តពីព្រះបិតា តែដោយសារព្រះអង្គនៅក្មេងពេក ទើបរាជ្យសម្បត្តិធ្លាក់លើព្រះបាទស្រីរាជា។

៣-ហេតុអ្វីបានជាព្រះបាទធម្មរាជាអាចពឹងសៀមមកដោះស្រាយបញ្ហាវិបត្តិក្នុងរាជវង្សខ្មែរបាន?

- ព្រះបាទធម្មរាជាជាប់ខ្សែស្រឡាយជាមួយសៀម ដោយព្រះអង្គជាបុត្រារបស់ព្រះបាទពញាយ៉ាត និងអ្នកម្នាងស៊ីសាង៉ាម។

- សៀមចង់បានទឹកដីដែលព្រះបាទស្រីរាជារំដោះបានមកវិញ។

៤-តើរបត្តិរាជវង្សខ្មែរនៅសវ.ទី១៥ បានធ្វើឱ្យប្រទេសកម្ពុជា បែងចែកជាប៉ុន្មាន អាណាចក្រ? អ្វីខ្លះ?

❑ **បែងចែកជាបីអណាចក្រគឺ៖**

- **អាណាចក្រខាងជើង** គ្រប់គ្រងដោយ ព្រះបាទស្រីរាជា មានរាជធានីនៅកំពង់សៀម។
- **អាណាចក្រខាងកើត** គ្រប់គ្រងដោយ ព្រះបាទស្រីសុរិយោទ័យ មានរាជធានីនៅស្រីសឈរ
- **អាណាចក្រខាងត្បូង** គ្រប់គ្រងដោយ ព្រះបាទធម្មរាជា មានរាជធានីនៅចតុមុខ។

៥-តើការបែកបាក់ និងវិបត្តិក្នុងរាជវង្សខ្មែរនាសវ.ទី១៥ បានផ្តល់វិបាកយ៉ាងអាក្រក់ដល់សង្គមខ្មែរដូចម្តេចខ្លះ?

- ចោរកម្ម ទុរ្ភិក្ស អសន្តិសុខ ជំងឺរាតត្បាត
- សង្គ្រាមអូសបន្លាយអស់រយៈពេល១០ឆ្នាំ (១៤៧៥-១៤៨៥)
- ប្រជារាស្ត្រខ្មែរត្រូវស្លាប់ដោយសារសង្គ្រាមស៊ីវិលជាច្រើន
- ធ្វើឱ្យបាក់បែកសាមគ្គីភាព
- មិនអាចរំលាយរាជធានីសៀមបានដូចការប៉ងរបស់ព្រះបាទស្រីរាជា
- បាត់បង់ទឹកដីដោយសារបរទេសឈ្លានពាន
- ត្រូវអាប់ឱនកិត្តិយសក្នុងរាជវង្សខ្មែរ ...។

៦-ហេតុអ្វីបានជាសៀមយល់ព្រមជួយដោះស្រាយវិបត្តិក្នុងរាជវង្សខ្មែរ?

- សៀមចង់សងសឹកនឹងព្រះបាទស្រីរាជា ដែលបានលើកទ័ពរំដោះខេត្តខាងលិច និងចង់វាយកម្ទេចក្រុងអយុធ្យារបស់ខ្លួន។
- ទទួលបានខេត្តដែលព្រះបាទស្រីរាជារំដោះបានយកមកវិញ និងដាក់កម្ពុជាក្រោមចំណុះរបស់ខ្លួន។

៥-សង្គ្រាមរវាងព្រះបាទស្រីសុគន្ធបទនិងស្តេចកន

១-ហេតុអ្វីបានជាព្រះបាទស្រីសុគន្ធបទទ្រង់សព្វព្រះរាជហឫទ័យគង់នៅរាជវាំងទួលបាសាន?

- ព្រោះព្រះបាទស្រីសុគន្ធបទសព្វព្រះទ័យប្រពាត់ប៉ឹង បង់សំណាញ់កម្សាន្ត និងយាងចូលព្រៃបរបាញ់សត្វ។

២-ហេតុអ្វីបានជាមានសង្គ្រាមរវាងព្រះបាទស្រីសុគន្ធបទ និងស្តេចកន?

- ព្រះបាទស្រីសុគន្ធបទមានផែនការសម្លាញ់ស្តេចកនចោល ដោយជឿលើការទស្សន៍ទាយរបស់ហោរាថា ស្តេចកនមានបំណងក្បត់និងជ្រែករាជ្យព្រះអង្គ។
- ចំណែកស្តេចកនខឹងនឹងព្រះបាទស្រីសុគន្ធបទ ដែលចង់សម្លាប់ខ្លួន តាមការទស្សន៍ទាយរបស់ហោរា និងការញុះញង់របស់ពួកមន្ត្រីរាជការ ដែលមិនពេញចិត្តនឹងខ្លួន។

៣-ចូរកត់សម្គាល់ហេតុដែលធ្វើឱ្យស្តេចកនយកជ័យជម្នះលើព្រះបាទស្រីសុគន្ធបទ។

- ព្រះបាទស្រីសុគន្ធបទមិនគិតពីរឿងនយោបាយ សេដ្ឋកិច្ច និងសង្គមជាតិ គិតតែពីរឿងការកម្សាន្តជាធំ។

- ម្យ៉ាងទៀតការភៀសខ្លួនរបស់មហាឧបរាជចន្ទរាជា បានធ្វើឱ្យព្រះអង្គអស់អ្នកមានសមត្ថភាពនៅក្បែរខ្លួន ជាហេតុធ្វើឱ្យព្រះអង្គមិនអាចច្បាំងឈ្នះស្តេចកនបាន។

៤-តើក្នុងរជ្ជកាលព្រះបាទស្រីជេដ្ឋាធិរាជរាមាធិបតី(ស្តេចកន) ប្រទេសជាតិមានស្ថានភាពដូចម្តេច?

- ប្រទេសជាតិទទួលបានសន្តិភាព
- ពួកបរទេសចូលមកធ្វើទំនាក់ទំនងពាណិជ្ជកម្ម
- បោះពុម្ពប្រាក់ស្លឹងសញ្ញារូបនាគឱ្យប្រើប្រាស់ពាស់ពេញប្រទេស ដើម្បីសម្រួលវិស័យពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- ប្រជានុរាស្ត្រមានជីវភាពធូរធារ ដោយសារមានការបន្ធូរបន្ថយពន្ធដារ បន្ថយពិន័យ ព្រមទាំងកែប្រែច្បាប់ព្រហ្មទណ្ឌឱ្យមានលក្ខណៈធូរស្រាលជាងមុន។

៦-សង្គ្រាមរវាងស្តេចកន និងព្រះចន្ទរាជា(១៥១៦-១៥២៥)

១-ហេតុអ្វីបានជាមានសង្គ្រាមរវាងស្តេចកន និងព្រះចន្ទរាជា?

- ស្តេចកនបានសម្លាប់ព្រះបាទស្រីសុគន្ធបទដែលជាព្រះរៀមរបស់ព្រះអង្គ
- ព្រះចន្ទរាជាធ្វើសង្គ្រាមដើម្បីសឹកឱ្យព្រះរាម(ស្រីសុគន្ធបទ) និងរំដោះប្រទេសពីស្តេចកន។
- ចំណែកស្តេចកនធ្វើសង្គ្រាមជាមួយព្រះចន្ទរាជាដើម្បីការពារអំណាចរបស់ខ្លួន។

២-ហេតុអ្វីបានជាព្រះចន្ទរាជាធ្វើសង្គ្រាមឈ្នះស្តេចកន?

❑ **ព្រោះព្រះចន្ទរាជាបាន៖**

- បោះទីតាំងបោះទីតាំងនៅកន្លែងដែលមានសក្តានុពលសេដ្ឋកិច្ច ជាងស្តេចកន
- យកព្រះទ័យទុកដាក់លើការងារជំនួញជាមួយបរទេស
- ដាក់កំហិតលើការប្រមូលពន្ធដារសព្វសារពើ
- ជាព្រះរាជាស្របច្បាប់ដែលមានការគាំទ្រច្រើនពីប្រជារាស្ត្រ...។

៣-តើសង្គ្រាមរវាងស្តេចកន និងព្រះចន្ទរាជាផ្តល់ផលវិបាកអ្វីខ្លះដល់សង្គមខ្មែរនាពេលនោះ?

- បែកបាក់សាមគ្គីជាតិ
- ប្រជាពលរដ្ឋមិនបានធ្វើស្រែចម្ការ
- ទាហាន និងប្រជារាស្ត្រស្លាប់ជាច្រើននាក់
- បន្សល់ទុកស្ត្រីមេម៉ាយ និងក្មេងកំព្រា
- ធ្វើឱ្យខ្មែរកាប់សម្លាប់គ្នាឯងយ៉ាងសាហាវបំផុត
- ខូចហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើឱ្យប្រទេសដទៃគេមាក់ងាយ
- ខាតបង់ប្រយោជន៍ជាតិ
- សេដ្ឋកិច្ចជាតិធ្លាក់ចុះ...។

៧-សំណួរប្រតិបត្តិ

១-តើសង្គ្រាមរំដោះយកអាណាខេត្តខ្មែរទិសខាងលិចពីសៀម ផ្តល់អត្ថន័យជាប្រវត្តិសាស្ត្រដល់ខ្មែរជំនាន់ក្រោយដូចម្តេចខ្លះ?

២-តើអន្តរាគមន៍របស់ស្តេចសៀមនៅក្នុងវិបត្តិរាជវង្សខ្មែរ បានផ្តល់បទពិសោធដូចម្តេចខ្លះដល់សង្គមខ្មែរជំនាន់ក្រោយ?

៣-ហេតុអ្វីបានជាប្រទេសកម្ពុជានាសតវត្សទី១៥ បែងចែកជាបីអាណាចក្រ?

៤-តើទីតាំងចតុមុខអំណោយផលដល់ពាណិជ្ជកម្មយ៉ាងដូចម្តេចខ្លះ?

៥-ហេតុអ្វីសង្គ្រាមកើតមានឡើងក្នុងរាជ្យព្រះបាទស្រីសុគន្ធបទ?

ចេញលក់ហើយ!



ទំនាក់ទំនងទិញតាមរយៈ

ឈិន ចណ្ឌី